**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

# សារលិខិតជូនពរ
# សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន
# ប្រធានកាកបាទក្រហមកម្ពុជា

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសដ៏មហាជ័យមង្គលនៃពិធីខួបកំណើតគម្រប់ **៦៧** ឈានចូល **៦៨ឆ្នាំ** របស់ **សម្តេច** ដែលនឹងឈានចូលមកដល់នៅថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតកម្ពុជាទាំងអស់ ដែលកំពុងបំពេញបេសកកម្មនៅក្រៅប្រទេស ខ្ញុំបាទ និងភរិយា សូមចូលរួមអបអរសាទរប្រកបដោយមនោសញ្ចេតនារំភើបរីករាយក្រៃលែង និងសូមសម្តែងនូវសេចក្តីគោរពកោតសរសើរដោយស្មោះ ជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាកុលធីតាកម្ពុជាដ៏ឆ្នើមមួយរូប ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ ដើម្បីដឹកនាំបេសកកម្មមនុស្សធម៌របស់ចលនាកាកបាទក្រហមកម្ពុជា សម្រេចបានស្នាដៃល្បីរន្ទឺសុសសាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ព្រមទាំងបានលះបង់ពេលវេលាផ្ទាល់ខ្លួនសំរាប់គ្រួសារ ជាឧត្តមភរិយា **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាមាតាដ៏ល្អ និងជាជីដូនប្រកបដោយព្រហ្មវិហារធម៌ ជាពិសេស ការគោរពស្រឡាញ់ពីប្រជាពលរដ្ឋកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំសូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមមេត្តាជួយតាមបីបាច់ថែរក្សា និងប្រទានពរជ័យសេរីមង្គលជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា** មេត្តាទទួលនូវការគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ និងភរិយា។

ថ្ងៃ ចន្ទ ៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១

**ប្រាក់ សុខុន** **ខេង សំវ៉ាដា**

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh